## P1

ពលករបរទេស

សេវាកម្មធានារ៉ាប់រងប្រាក់សំរាប់ការចាកចេញតាមពេលកំនត់គឺមានការខុសប្លែកពីមុន។

ចំពោះនិយោជកដែលបានប្រើប្រាស់សេវាកម្មធានារ៉ាប់រងការចាកចេញតាមពេលកំនត់របស់ពលករនោះវាអាចជួយសំរួលការលំបាកក្នុងការផ្តល់ប្រាក់បំណាច់ឆ្នាំដែលផ្តល់ជូនទាំងស្រុងក្នុងពេលតែមួយនិងពលករបរទេសដែលមកធ្វើការតាមប្រពន្ធ័អនុញ្ញាតិការងារគឺអាចជួយថែរក្សារប្រាក់បំណាច់ឆ្នាំរបស់ពលករអោយមានសុវត្ថិភាពដើម្បីអោយពលករអាចធ្វើមាតុភូមិនិវត្តិន៏ដោយភាពងាយស្រួល។

មន្ទីការងារ

នាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សនៃប្រទេសកូរ៉េ

## P2

ចាប់ពីថ្ងៃទី២៩ខែ៧ឆ្នាំ២០១៤នេះទៅពលករបរទេសដែលបានដាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងការចាកចេញតាមពេលកំនត់ប្រាក់នោះនិងត្រូវផ្តល់ជូននៅក្រោយពេលដែលពលករបានធ្វើមាតុភូមិនិវត្តន៏រួច។

ពលករបរទេសត្រូវដាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងមុនពេលដែលខ្លួនចាកចេញពីប្រទេសកូរ៉េ

① អាចទទួលតាមរយៈផ្ញើទៅតាមកុងធនាគារក្រៅប្រទេសរបស់ពលករ

② អាចទទួលនៅប្រលានយន្តហោះនៅថ្ងៃចេញដំណើរក៏បានគឺអាស្រយ័ទៅតាមការជ្រើសរើស
របស់ម្ចាស់ខ្លួនផ្ទាល់។

※ ក៏ប៉ុន្តែ, សេវាកម្មធានារ៉ាប់រងលើប្រាក់សោហ៊ុយធ្វើមាតុភូមិនិវត្តន៏នៅរក្សាដូចមុនគឺផ្តល់ជូនមុនពេលចាកចេញទៅ

សេវាកម្មធានារ៉ាប់រងប្រាក់សំរាប់ការចាកចេញតាមពេលកំនត់គឺជាអ្វី?

「តាមរយៈច្បាប់ស្តីអំពីកម្មករបរទេស」 គឺនិយោជកត្រូវផ្តល់ប្រាក់បំណាច់ឆ្នាំជូនពលករ មួយដងគឺអោយគ្រប់ចំនួនដើម្បីសំរួលដល់ការលំបាកនេះនិយោជកដែលទទួលពលករបទេសមកបំរើការមានកាតព្វកិច្ចទិញសេវាកម្មនេះ

- អ្នកដែលមានលទ្ធភាពចូលរួម ៈ មានបុគ្គលិកចុះកិច្ចសន្យាចាប់ពីម្នាក់ឡើងទៅ, និយោជកដែលយកពលករបរទេសមកបំរើការងារ ពលកររូបនោះត្រូវនៅសល់រយៈពេលធ្វើការចាប់ពី១ឆ្នាំឡើងទៅ

* អ្នកដែលមិនអាចចូលរួម ៈ ពលករដែលមកតាមរយៈច្បាប់ស្តីប្រពន្ធ័អនុគ្រោះការងារពិសេសផ្នែកសំណង់

- ការកំនត់ពេលទិញ និងការដាក់ពិនយ័ ៈ ក្នុងរយៈពេល១៥ថ្ងៃគឺចាប់គិតពីថ្ងៃដាក់អោយមានសុពលភាពនៃកិច្ចសន្យាកុងត្រាការងារ

* អ្នកដែលមិនបានទិញតាមពេលកំនត់គឺអាចផាកពិនយ័ជាប្រាក់ក្រោម៥លានវ៉ុន

–ថ្លៃបង់ធានារ៉ាប់រង ៈ ពលករបរទេសត្រូវបង់ជារៀងរាល់ខែនូវទឹកប្រាក់ចំនួន៨.៣%នៃប្រាក់ខែទៅអោយក្រុមហ៊ុនធានារ៉ាប់រង

–ចំនុចគួរយល់ដឹង ៈ ចំពោះពលករបទេសដែលបានស្នើសូមដកប្រាក់ធានារ៉ាប់រងការចាកចេញតាមពេលកំនត់ទៅក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងពេលនោះបុគ្គលិកធានារ៉ាប់រងត្រូវផ្តល់ពត៏អំពីចំនួនទឹកប្រាក់ដែលត្រូវផ្តល់ដល់អ្នកប្រើប្រាស់ក្នុងករណីដែលទឹកប្រាក់ដែលត្រូវផ្តល់នោះវាមិនស៊ីគ្នាទៅនិងប្រាក់បំណាច់ឆ្នាំដែលច្បាប់បានកំនត់នោះនិយោជកជាអ្នកបន្ថែមបង្រប់។

ការដកាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងនិងនិតិវិធីនៃការផ្តល់ជូន

–ពលករបរទេសគឺត្រូវធ្វើឡើងយ៉ាងហោចណាស់ក៏១ខែមុនពេលចាកចេញគឺមុនពេលដាច់ទិដ្ឋាការស្នាក់នៅ (ក្រោយពីបានដាក់ពាក្យជូនដំណឹងស្តីពីការវិលត្រលប់) ដាក់ពាក្យសូមប្រាក់ធានារ៉ាប់រង (សាមសុងហ្វាដែ) ទៅអ្នកទទួលបន្ទុកសេវាកម្មធានារ៉ាប់រងរួចហើយ,

① អាចទទួលតាមរយៈផ្ញើទៅតាមកុងធនាគារក្រៅប្រទេសរបស់ពលករ ② គឺទទួលជាប្រាល់សុទ្ធនៅប្រលានយន្តហោះដោយផ្ទាល់តែម្តងគឺប្រព្រឹត្តនៅពេលដែលឆ្លងការត្រួរពិនិត្យការចេញដំនើរចប់សព្វគ្រប់ហើយនេះក៏ជារបៀបមួយដែរក្នុងចំនោមរបៀបដែលត្រូវជ្រើសរើស

P3

កាលណាប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមពេលកំនត់និងប្រាក់បំណាច់ឆ្នាំមិនស៊ីមេទ្រីគ្នានិយោជកជាអ្នកបង្រប់ហើយប្រាក់នោះគឺគ្មានជាប់ពាក់ពន្ធ័ទៅនិងការវិលត្រលប់រឺក៏មិនវិលត្រលប់នោះទេនៅពេលដែលត្រូវវិលត្រលប់រឺមួយក៏ផ្លាស់ប្តូរការងារពេលកិចសន្យាត្រូវបានចប់អ្នកប្រើប្រាស់អាចស្នើសូម ហើយទទួលយកនៅប្រទេសកូរ៉េតែម្តង

*ដើម្បីស្នើសូមប្រាក់បង្រប់បានពលករបរទេសត្រូវធ្វើការស្នើសូមទៅក្រុមហ៊ុនធានារាប់រងអោយធ្វើលិខិតបញ្ជាក់ហើយត្រូវដាក់បញ្ចូលនិតិវិធីដែលបានបញ្ជាក់នេះ

▶ របៀបទទួលនៅក្រៅប្រទេសគឺប្រព្រឹត្តទៅនៅពេលដែលត្រលប់ទៅដល់ប្រទេសខ្លួនវិញ

ការដាក់ពាក្យផ្លាស់ប្តូរការងារ, លិខិតផ្តល់ដំណឹងស្តីពីការវិលត្រលប់

និយោជក, ពលករបរទេស

មុនពេលចាកចេញរយៈពេល១ខែ

ជូនដំណឹងអំពីទឹកប្រាក់ដែលត្រូវទទួល

អ្នកទទួលបន្ទុកសេវាកម្មធានារាប់រង

(ផ្ញើរជូនដោយស្វ័យប្រវត្ត)

ដាក់ពាក្យស្នើសូមប្រាក់ធានារាប់រង

ពលករបរទេស

ក្នុងអំឡុងពេល១ខែ

ការដាក់ពាក្យនិងការពិនិត្យ

អ្នកទទួលបន្ទុកសេវាកម្មធានារាប់រង

ក្រោយដាក់ពាក្យក្នុងអំឡុងពេល១～២ថ្ងៃ

ក្រសួងយុត្តិធរត្រួតពិនិត្យការវិលត្រលប់រួចប្រាក់ធានារាប់រងត្រូវផ្តល់ជូន

អ្នកទទួលបន្ទុកសេវាកម្មធានារាប់រង－ ធនាគារ

ក្រោយការវិលត្រលប់រួចអំឡុងពេល១～២ថ្ងៃ

ការផ្ញើទៅបរទេស

តាមរយៈធនាគារ

រហស័

នៅឯប្រទេសដែលបញ្ជូនពលករ

ធនាគារនៃប្រទេសនោះ

ក្រោយពីផ្ញើររួចអំឡុងពេល១～២ថ្ងៃ

ការទទួលប្រាក់ធានារាប់រង

ពលករបរទេស

ក្រោយពេលចាកចេញរួច ក្នុងអំពេល១៤ថ្ងៃ

▶ ទទួលជាប្រាក់សុទ្ធនៅថ្ងៃចេញដំណើរឯប្រលានយន្តហោះ (អាកាសយានដ្ឋានអន្តរជាតិអ៊ីនឆុន)

ពាក្យស្នើសូមប្រាក់ធានារាប់រង(ពេលដាក់ពាក្យគឺជ្រើសរើសរបៀបទទួលប្រាក់នៅប្រលានយន្តហោះ)

ពលករបរទេស

ចេញលិខិតបញ្ជាក់ថាបានទទួលប្រាក់ធានារាប់រង

ក្រុមហ៊ុនធានារាប់រង － ពលករបរទេស

នៅថ្ងៃចេញដំណើរធនាគារនៅប្រលានយន្តហោះដាក់បន្ទូលលិខិតទទួលប្រាក់

ពលករបរទេស — ធនាគារ

ចេញវិកយ័បត្តិបញ្ជាក់ចំនួនទឹកប្រាក់ដែលត្រូវទទួលបានបន្ទាប់ពីប្តូររួច

ធនាគារ — ពលករបរទេស

ក្រោយពីត្រួតពិនិត្យការចេញដំណើររួចទទួលយកនៅកន្លែងប្តូរប្រាក់ទទួលរួចហើយចេញដំណើរ
ពលករបរទេស

## P4

ធ្វើការកែសំរួលច្បាប់ដែលជាប់ទាក់ទងទៅនិងសេវាកម្មធានារាប់រងសំរាប់តែពលករបរទេសសុទ្ធសាត

* តាមរយៈច្បាប់ស្តីអំពីកម្មករបរទេស ដែលបានកែសំរួល (២៨.១.២០១៤ប្រកាស,២៩.៧.១០១៤អនុត្តន៍)

☞ ច្បាប់ដែលកែសំរួលហើយអាចរកមើលបាន(www.law.go.kr)តាមរយៈគេហទំព័រមជ្ឈមណ្ឌលពត៏ច្បាប់ជាតិ

① ប្រាក់ធានារាប់រងរបស់ពលករបរទេស(សេវាកម្មធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមពេលកមនត់និងធានារ៉ាប់រងលើសោហ៊ុយធ្វើមាតុភូមិនិវត្តន៍)ពេលវេលានៃការផ្តល់សិទ្ធិស្នើសួមគឺត្រូវបានពន្យាពី(២ឆ្នាំ → ៣ឆ្នាំ)

② ចំពោះប្រាក់ធានារាប់រងដែលមិនត្រូវបានគេដកគឺត្រូវបានថែរក្សារដោយគណកម្មាធិការគ្រប់គ្រងប្រាក់ដែលបានបង្កើតឡើងនិងបានដំណើរ(បានខិតខំស្វែងរកអ្នកដែលមិនដកប្រាក់ធានារាប់រងនេះ)

③ ការផ្លាស់ប្តូរពេលវេលានៃការផ្តល់ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកមនត់

ចំពោះប្រាក់ដែលម្ចាស់បាត់បង់សិទ្ធក្នុងការដកគឺមិនត្រូវបានចំនេញទៅក្រុមហ៊ុនធានារាប់រងទេ, នាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្ស
នៃប្រទេសកូរ៉េទទួលមកថែរក្សារទុក
ចំពោះប្រាក់ធានារាប់រងដែលមិនត្រូវបានគេដកគឺត្រូវបានគណកម្មាធិការគ្រប់គ្រងប្រាក់ធ្វើការពិភាក្សារពិគ្រោះយោបល់ដើម្បីស្វែងរកពលករបរទេសដែលមិនបានដកប្រាក់
ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់និងត្រូវផ្តល់អោយក្នុងអំពេល១៤ថ្ងៃគឺរាប់ថ្ងៃចាកចេញ ទៅតាមអ្វីដែលបានកំនត់
(ការផ្លាស់ប្តូរទិដ្ឋាការឬក៏ស្លាប់គឺត្រូវដាក់ពាក្យផ្តល់ដំណឹង, បើចាកចេញទៅហើយទើបដាក់ពាក្យសូមជាក្រោយនោះគឺរាប់ពីថ្ងៃដាក់
ពាក្យទៅក្នុងអំពេល១៤ថ្ងៃទើបផ្តល់អោយ)

P5

ប្រភេទសេវាកម្មធានារ៉ាប់រងសំរាប់តែពលករបរទេសសុទ្ធសាតនិងអត្ថន័យ

| ការបែងចែក | សេវាកម្មធានារ៉ាប់រង<br>ប្រាក់ការវិលត្រលប់តាមពេល<br>កំនត់ | ធានារ៉ាប់រងលើប្រាក់សោហ៊ុយ<br>ធ្វើមាតុភូមិនិវត្តន៍ | សេវាកម្មធានារ៉ាប់រលើ<br>ការបើកប្រាក់ឈ្នួល | ធានារ៉ាប់រងនៅពេលមា<br>នគ្រោះថ្នាក់ |
| --- | --- | --- | --- | --- |
| គោលបំនងនៃការដាក់បន្ទូល | កាត់បន្ថយការលំបាកក្នុងការ<br>ផ្តល់ប្រាក់បំណាច់ឆ្នាំ | បង្រប់បន្ថែមលើសោហុយ<br>ធ្វើមាតុភូមិនិវត្តន៍ | ប្រាក់បំរុងសម្រាប់បើកប្រាក់ជូន<br>ពលករនៅពេលដែលមានបញ្ហា | គ្រោះថ្នាក់ដែលកើតឡើងក្រៅ<br>ពេលបំពេញការងារដូច<br>ជាការស្លាប់<br>អាធិជំងឺផ្សេងៗ |
| ភស្តុតាង | ច្បាប់ស្តីអំពីពលករបរទេសជំពូក<br>ទី១៣ . មាត្រាទី២១ | ច្បាប់ស្តីអំពីពលករបរទេសជំពូកទី១<br>៥មាត្រាទី២២ | ច្បាប់ស្តីអំពីពលករបរទេសជំពូកទី<br>២៣មាត្រាទី២៧ | ច្បាប់ស្តីអំពីពលករបរទេសជំពូកទី២<br>៣មាត្រាទី២៨ |
| សំរាប់ការចូលរួម | និយោជក | ពលករបរទេស | និយោជក | ពលករបរទេស |
| រោងចក្រសហគ្រាសដែលត្រូវអនុវត្តន៍ | - មានបុគ្គលិកចុះកិច្ចសន្យាចា<br>ប់ពីម្នាក់ឡើងទៅសហគ្រាស<br>ដែលមានបុគ្គលិកក្រោម៤នាក់ចាប់<br>អនុវត្តពី១៨ឆ្នាំ. និយោជក<br>ដែលយកពលករបរទេសមក<br>បំរើការងារពលកររូបនោះត្រូវ<br>នៅសល់រយ:ពេលធ្វើ<br>ការចាប់ពី១ឆ្នាំឡើងទៅ | -ចិន, ហ្វីលីពីន, ឥណ្ឌូនេស៊ី,<br>ថៃ, វៀតណាម : ៤០មឺន<br>មុងហ្គោលប្រទេសផ្សេងៗ :<br>៥០មឺន<br>-ស្រីលង្កា : ៦០មឺន | - ក្នុងចំនោមអ្វីដែលបានរៀបរា<br>ប់មានតែផ្នែកណាមួយក៏រាប់<br>ចូលដែរ . សហគ្រាសដែលមិនស្ថិ<br>តក្រោមច្បាប់ធានា . សហគ្រាសដែ<br>លមានបុគ្គលិកចុះកុងត្រា<br>ក្រោម៣០០នាក់ | សហគ្រាសដែលប្រើពលករបរទេសរឺក៏និយោជក |
| អ្នកដែលទទួលផលចំនេញពីសេវាកម្ម | ពលករបរទេស | ពលករបរទេស | ពលករបរទេស | ពលករបរទេស |
| ការកំនត់ពេលទិញ<br>និងការដាក់ពិន័យ | ក្នុងរយ:ពេល១៥ថ្ងៃគឺចា<br>ប់គិតពីថ្ងៃដាក់អោយមា<br>នសុពលភាពនៃកិច្ចសន្យា<br>កុងត្រាការងារ<br>-គឺអាចផាកពិន័យ<br>ជាប្រាក់ក្រោម៥លានវ៉ុន | ក្នុងរយ:ពេល៨០ថ្ងៃគឺចា<br>ប់គិតពីថ្ងៃដាក់អោយមា<br>នសុពលភាពនៃកិច្ចសន្យា<br>កុងត្រាការងារ<br>-គឺអាចផាកពិន័យ<br>ជាប្រាក់ក្រោម៥លានវ៉ុន | ក្នុងរយ:ពេល១៥ថ្ងៃគឺចា<br>ប់គិតពីថ្ងៃដាក់អោយមា<br>នសុពលភាពនៃកិច្ចសន្យា<br>កុងត្រាការងារ<br>-គឺអាចផាកពិន័យ<br>ជាប្រាក់ក្រោម៥លានវ៉ុន | ក្នុងរយ:ពេល១៥ថ្ងៃគឺចា<br>ប់គិតពីថ្ងៃដាក់អោយមា<br>នសុពលភាពនៃកិច្ចសន្យា<br>កុងត្រាការងារ<br>-គឺអាចផាកពិន័យ<br>ជាប្រាក់ក្រោម៥លានវ៉ុន |
| របៀបបង់ប្រាក់ | ៨.៣%នៃប្រាក់ខែរៀងរាល់ខែ | បង់ម្តងទាំងអស់<br>ខុសគ្នាទៅតាមប្រទេស៤០～៦០មឺន | បង់ម្តងទាំងអស់សំរាប់ពលករម្នាក់ : ១៥០០០ក្នុង១ឆ្នាំ | បង់ម្តងទាំងអស់<br>ប្រហែល២០០០០ក្នុង៣ឆ្នាំ<br>(ខុសគ្នាទៅតាមភេទអាយុ) |
| មូលហេតុដែលផ្តល់ប្រាក់ធានា | ពលករបរទេសដែលបានធ្វើ<br>ការងារនៅសហគ្រាសមួយ<br>ចាប់ពី១ឆ្នាំឡើងទៅ | ពលករបរទេសធ្វើការវិលត្រលប់<br>(លើកលែងការទៅលេង) | —អាចទទួលបានក្នុងករណីដែល<br>ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ខែអោយ | ពលករបរទេសគ្រោះថ្នាក់ដែ<br>លកើតឡើងក្រៅ<br>ពេលបំពេញការងារដូច<br>ជាការស្លាប់រឺពិការ |
| ចំនួនទឹកផ្តល់ជូន | -អ្នកដែលធ្វើការងារចាប់ពី១<br>ឆ្នាំឡើងទៅ ហើយបានទិញ<br>សេវាកម្មចាប់ពី៣៥០ថ្ងៃ<br>ឡើងទៅ<br>១០១.៥～១០៦% | -ចាប់តាំងពីថ្ងៃបង់ប្រាក់<br>ដំបូងបង្អស់គឺ១២ខែឡើងទៅ<br>១០១.៥～១០៦% | ក្រសួងការងារជាអ្នកកំនត់ទឹក<br>ប្រាក់គឺកំនត់ត្រឹម២លានវ៉ុន<br>(សំរាប់ពលករម្នាក់) | -មានរបួសធ្ងន់បណ្តាល<br>អោយស្លាប់,ពិការ:<br>ខ្ពស់បំផុតត្រឹម៣០លានវ៉ុន<br>ស្លាប់ដោយជំងឺ,ពិការបាត់<br>បង់សមត្ថភាពដែលបណ្តាល<br>មកពីជំងឺ:១៥លានវ៉ុន |

P6

ប្រភេទបញ្ហាដែលត្រូវលើកជាចំងល់ Q&A

1) តាមរយ:ច្បាប់ស្តីអំពីកម្មករបរទេសដែលបានកែសំរួលការដាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់និង របៀបទទួលត្រូវបានផ្លាស់ប្តូរយ៉ាងដូចម្តេច?

- ដាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងគឺប្រព្រឹត្តិដូចមុនពេលដែលច្បាប់មិនទាន់កែសំរួលដែរពលករបរទេសគឺត្រូវធ្វើឡើងយ៉ាងហោច

ណាស់ក៏១ខែមុនពេលចាកចេញគឺមុនពេលដាច់ទិដ្ឋាការស្នាក់នៅ (ក្រោយពីបានដាក់ពាក្យជូនដំណឹងស្តីពីការវិលត្រលប់) ដាក់ពាក្យសូមប្រាក់ធានារ៉ាប់រង (សាមសុងហ្វាដៃ) ទៅអ្នកទទួលបន្ទុកសេវាកម្មធានារ៉ាប់រង

* ក៏ប៉ុន្តែ,ក្នុងករណីដែលផ្លាស់ប្តូរកន្លែងការងារអាចដាក់ពាក្យបាននៅឯសហគ្រាសចុងក្រោយបង្អស់ដែលខ្លួនបានបំរើការនោះ

- ពីមុនការទទួលប្រាក់ធានារ៉ាប់រងគឺទទួលក្នុងប្រទេសកូរ៉េតែឥឡូវនេះក្រោយពេលវិលត្រលប់ទៅដល់ប្រទេសវិញផ្ញើរអោយឬមួយក៏,
ទទួលនៅប្រលានយន្តហោះអ៊ីនឆុននៅថ្ងៃចាកចេញគឺមានការផ្លាស់ប្តូរដូចនេះ

* ពលករដែលបានបំពេញការងារចាប់ពី១ឆ្នាំឡើងទៅហើយមានការផ្លាស់ប្តូរទិដ្ឋាការឬក៏ស្លាប់គឺរក្សារនៅដដែលគឺរាប់ពីថ្ងៃដាក់ពាក្យ
ទៅក្នុងអំពេល១៤ថ្ងៃទើបផ្តល់អោយតែការទទួលគឺប្រព្រឹត្តទៅនៅក្នុងប្រទេសកូរ

## 2)ផ្ញើរអោយតាមលេខកុង,ផ្តល់អោយនៅប្រលានយន្តហោះ។ល។របៀបទទួលប្រាក់ធានារ៉ាប់រងការវិលត្រលប់ តាមការកំនត់តើត្រូវសំរេចយ៉ាងដូចម្តេច?

ពលករបរទេសដែលបានដាក់ស្នើសូមប្រាក់ធានារ៉ាប់រងនៅមុនពលចាកចេញសាមីខ្លួនអាចការជ្រើសរើសចំនុចណាមួយដែលខ្លួនយល់ថាល្អក្នុងចំនោម៤ចំនុចខាងក្រោម, ក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងធ្វើការពិនិត្យការចាកចេញនៃពលករបរទេសរួចហើយគឺផ្តល់ប្រាក់ជូនតាមរបៀបដែលសាមីខ្លួនបានជ្រើលរើស

| ការបែងចែក | | របៀបផ្តល់ប្រាក់ជូន |
|---|---|---|
| របៀបទទួលនៅក្រៅប្រ<br>ទេសគឺប្រព្រឹត្តទៅនៅពេល<br>ដែលត្រលប់ទៅដល់ប្រទេស<br>ខ្លួនវិញ | ផ្ញើរអោយតាមលេខកុងផ្ទាល់ខ្លួន | ទទួលតាមរយៈលេខកុងផ្ទាល់ខ្លួន |
| | លេខកុងសំរាប់ផ្ញើប្រាក់<br>ទៅបរទេស<br>- ទោះបីជាសាមីខ្លួន<br>គ្មានលេខកុងក៏អាច<br>ផ្ញើរបានដែរ | លេខកុងនៅប្រទេសខ្លួន (ក្រុមគ្រួសារ, អ្នកទីបី) ដែលបានតភ្ជាប់កុងសំរាប់តែ<br>ផ្ញើរប្រាក់ទៅបរទេស (លេខកុងក្នុងស្រុក) |
| | ផ្ញើរផ្ទាល់ទៅធនាគារនៃប្រ<br>ទេសខ្លួន<br>-ទោះបីជាសាមីខ្លួនគ្មាន<br>លេខកុងផ្ទាល់ឬក៏, គ្មានលេខកុងសំរាប់តែផ្ញើប្រាក់<br>ទៅបរទេស ក៏អាចផ្ញើបានដែរ | ពេលដែលដាក់ពាក្យស្នើសូម<br>ប្រាក់ធានារ៉ាប់រងគឺត្រូវទទួល<br>បាននៅលេខកុងពីធនាគារ<br>ក្រោយពេលទៅដល់ប្រទេសវិញ<br>សាមីខ្លួនអាចទៅដកប្រាក់នៅ<br>ធនាគារដែលគេបានកំនត់អោយ |
| ទទួលនៅប្រលានយន្តហោះ<br>នៅថ្ងៃចេញដំណើរ | ផ្តល់អោយនៅប្រលានយន្តហោះ | នៅថ្ងៃចេញដំណើរត្រូវទៅធនាគារ<br>ដែលមានទីតាំងនៅប្រលានយន្តហោះ<br>ដោយយកលិខិតបញ្ជាក់ការទទួល<br>ធានារ៉ាប់រងទៅដាក់រួចទទួលវិក័យបត្រ,<br>ក្រោយពីធ្វើការពិនិត្យការចេញដំណើររួច<br>ប្រគល់វិក័យបត្រទទួលប្រាក់អោយទៅ<br>កន្លែងប្តូររួចទទួលប្រាក់ |

ចំពោះពលករបរទេសដែលគ្មានលេខកុងផ្ទាល់ខ្លួនក៏អាចទទួលនៅក្រៅប្រទេសបានដែរ

P7
3)
ប្រសិនបើសាមីខ្លួនគ្មានលេខកុងផ្ទាល់ខ្លួនក្រោយពេលមាតុភូមិនិវត្តន៍តើអាចទទួលប្រាក់ធនារ៉ាប់រងបានរឺទេ?

- ក្នុងករណីនេះគេអាចប្រើលេខកុងដែលបានភ្ជាប់សំរាប់ផ្ញើរប្រាក់ទៅក្រៅប្រទេសពេលដែលគេរស់នៅប្រទេសកូរ,

លេខកុងនៅប្រទេសខ្លួន(ក្រុមគ្រួសារ,អ្នកទីបី) ដែលបានតភ្ជាប់កុងសំរាប់តែផ្ញើរប្រាក់ទៅបរទេសគឺត្រូវបានផ្ញើរដោយស្វ័យប្រវត្ត, ដូចច្នោះបាន

- ទោះបីជាសាមីខ្លួនគ្មានលេខកុងផ្ទាល់ឬក៏, ទោះបីជាគ្មានលេខកុងសំរាប់តែផ្ញើប្រាក់ទៅបរទេស(លេខកុងក្នុងស្រុក) ក៏អាចផ្ញើបានដែរ
តែត្រូវផ្ញើរផ្ទាល់ទៅធនាគារនៃប្រទេសខ្លួន*តាមរយៈការដាក់ពាក្យនៅធនាគារ

* ពេលដែលដាក់ពាក្យស្នើសូមប្រាក់ធានារ៉ាប់រងគឺត្រូវទទួលបាននៅលេខកុងពីធនាគា→ក្រោយពេលទៅដល់ប្រទេសវិញសាមីខ្លួនអា
ចទៅធនាគារដែលគេបានកំនត់អោយនោះ ហើយដោយគ្រាន់តែបង្ហាញលេខកុងនិងអត្តសញ្ញាណបណ្ណ័ទៅខាងធនាគារនោះ
គេអាចដកប្រាក់បាន

## 4) ប្រសិនបើនៅថ្ងៃចេញដំណើរខ្ញុំចង់ទទួលប្រាក់នៅប្រលានយន្តហោះ, តើត្រូវធ្វើយ៉ាងដូចម្តេចដែរ?

ពេលដែលដាក់ស្នើសូមប្រាក់ធានារ៉ាប់រងគេត្រូវជ្រើសរើសយកចំនុច 'ទទួលប្រាក់នៅឯប្រលានយន្តហោះ' ក្រោយពីបានដាក់ពាក្យសូមរួចអ្នកទទួលបន្ទុកសេវាកម្មធានារ៉ាប់ត្រូវប្រគល់ 'ឯកសារបញ្ជាក់សំរាប់ដកប្រាក់' ទៅអោយពលករបរទេស

-នៅថ្ងៃចេញដំណើរពលករបរទេសត្រូវយកទៅជាមួយនូវលិខិតឆ្លងដែន,សំបុត្រយន្តហោះ, ឯកសារបញ្ជាក់សំរាប់ដកប្រាក់,
ទៅធនាគារដែលស្ថិតនៅក្នុងប្រលានយន្តហោះរួចប្រគល់ឯកសារបញ្ជាក់សំរាប់ដកប្រាក់,ធនាគារត្រូវពិនិត្យ
លិខិតឆ្លងដែន និង សំបុត្រយន្តហោះ ។ល។, ធនាគារនិងផ្តល់អោយពលករបរទេសនូវ 'លិខិតបញ្ជាក់ប្តូរប្រាក់ដែលផ្តល់'

-ក្រោយពីធ្វើការពិនិត្យការចេញដំណើររួចរាល់ហើយ,គេអាចទៅដកលុយនៅកន្លែងប្តូរប្រាក់ដែលមាននៅម្តុំហាងលក់ទំនិញ
គេត្រូវប្រគល់លិខិតបញ្ជាក់ប្តូរប្រាក់ដែលត្រូវផ្តល់ ទៅអោយអ្នកប្តូររួចសូមដករូបិយបណ្ណ័(ក្រដាសប្រាក់) ដែលខ្លួនត្រូវការ

ពាក្យស្នើសូមប្រាក់ធានារ៉ាប់រង(ជ្រើសរើសយកការទទួលនៅឯប្រលានយន្តហោះ)

ពលករបរទេស

ចេញលិខិតបញ្ជាក់ប្តូរប្រាក់ដែលផ្តល់អោយ

ក្រុមហ៊ុនសេវាកម្មធានារាប់រង – ពលករបរទេស

នៅថ្ងៃចេញដំណើរត្រូវដាក់ឯកសារបញ្ជាក់សំរាប់ដកប្រាក់ទៅធនគារនៅឯប្រលានយន្តហោះ

ពលករបរទេស – ធនាគារ

ចេញលិខិតបញ្ជាក់ប្តូរប្រាក់ដែលផ្តល់

ធនាគារ – ពលករបរទេស

ក្រោយពីធ្វើការពិនិត្យការចេញដំណើររួចរាល់ហើយទទួលប្រាក់នៅកន្លែងប្តូរប្រាក់រួចចេញដំណើរ
ពលករបរទេស

## P8

5) ក្នុងករណីដែលប្រពន្ធ័ផ្ទេរប្រាក់នៅប្រទេសដែលបញ្ជូនពលកមិនមានភាពល្អប្រសើរនោះក្រោយពេលវិលត្រលប់ទៅវិញ
ប្រសិនបើមិនអាចទទួលប្រាក់នោះតើត្រូវធ្វើយ៉ាងដូចម្តេច?

តាមរយៈធនាគារក្នុងស្រុកគឺបានអនុវត្តន៏រួចមកហើយជាមួយប្រទេសដែលបញ្ជូនពលករចំនួន១៥ប្រទេសដែលមាន៣របៀបគឺ,

(①ផ្ញើរអោយតាមលេខកុងផ្ទាល់ខ្លួន, ②លេខកុងសំរាប់តែផ្ញើប្រាក់ទៅបរទេស, ③ផ្ញើរផ្ទាល់ទៅធនាគារនៃប្រទេសនោះ)
ដោយសារប្រពន្ធ័ផ្ទេរប្រាក់នៅប្រទេសបញ្ជូនពលករមិនមានសុវត្ថិភាពហើយមិនបានទទួលប្រាក់ធានារាប់រងនោះ
រហូតមកដល់ពេលនេះគឺមិនទានមានទេ

☞ បើសិនជាមានចំងល់អំពីរបៀបផ្ញើរប្រាក់ទៅក្រៅប្រទេសសូមមើលចំនុចលេខ២

បន្ថែមលើនេះទៀត,បច្ចុបន្ននេះ(មុនពេលច្បាប់ចូលជាធរមាន)នៅក្នុងករណីមុនពេលធ្វើកាវិលត្រលប់ទៅមិនបានដាក់
ពាក្យសូមដកប្រាក់ធានារាប់រងក៏ដោយក៏ពួកគេអាចដាក់ពាក្យសូមដកប្រាក់នេះបានដែរគឺគេអាចដក់ពាក្យនៅប្រទេសរបស់ពួកគេ,
ចំពោះករណីនេះការផ្តល់ប្រាក់គឺធ្វើឡើងតាមរយៈលេខកុងសំរាប់ផ្ញើរប្រាក់ទៅបរទេស

*ក្នុងឆ្នាំ២០១៣មានពលករបរទេសចំនួន១៥០០នាក(៨០០លានវ៉ុន)ដែលបានដាក់ពាក្យសូមដកប្រាក់ធានារាប់រងនៅ
ប្រទេសរបស់ពួកគេ ហើយក៏បានទទួលប្រាក់តាមការស្នើសូម។
ទោះជាយ៉ាងនេះក្តី,ក្នុងករណីប្រពន្ធ័ផ្ទេរប្រាក់នៅប្រទេសពួកគេមិនសូវមានសុវត្ថិភាពហើយចង់ទទួលប្រាក់មុនមុនពេលចាកចេញនោះ,
ថ្ងៃចេញដំណើរនៅឯប្រលានយន្តហោះអ៊ីនឆុនក្រោយពេលពិនិត្យការចេញដំណើររួចរាល់គេអាចទទួលជាប្រាក់សុទ្ធរួចចេញដំណើរ។

☞ បើសិនជាមានចំងល់អំពីរបៀបទទួលប្រាក់នៅឯប្រលានយន្តហោះសូមមើលចនុចលេខ៤

6) ករណីដែលមិនអាចជៀសវាងបានមុនពេលវិលត្រលប់មកគឺមិនបានដាក់ពាក្យសូមដកប្រាក់ធានារាប់រងតើត្រូវធ្វើដូចម្តេចដើម្បី
បានទទួលប្រាក់នោះ?

ករណីដែលមិនបានស្នើសូមដកប្រាក់ធានារាប់រង,ក្រោយពេលត្រលប់ទៅដល់ប្រទេសរបស់ខ្លួនពួកគេអាចដាក់ពាក្យសូមដកប្រាក់ធានារាប់រងតាមរយៈមជ្ឈមណ្ឌលEPS,ស្ថាបន័ដែលបញ្ជូនពលករហើយពួកគេអាចទទួលប្រាក់តាមរយៈលេខកុងសំរាប់ផ្ញើរប្រាក់ទៅបរទេស

*ក្រោយពេលទៅដល់ប្រទេសវិញដាក់ពាក្យសូមដកប្រាក់ធានារាប់រងនៅប្រទេសរបស់ពួកគេ នៅមុនពេលកែរសំរួលច្បាប់
គឺអាចធ្វើបាន,
នៅពេលដែលច្បាប់បានកែសំរួលរួច ករណីដែលដាក់ពាក្យសូមដកប្រាក់ធានារាប់រងក្រោយពេលត្រលប់ទៅដល់ប្រទេសរបស់
ខ្លួននោះ គឺចាប់ដាក់ពាក្យទៅ ក្នុងអំឡុងពេល១៤ថ្ងៃប្រាក់និងត្រូវបានផ្តល់ជូនយ៉ាងប្រាកដ

បន្តមក,តាមរយៈច្បាប់ដែលបានកែសំរួលពេលវេលានៃការផ្តល់សិទ្ធិស្នើសូមគឺត្រូវបានពន្យាពី(២ឆ្នាំ → ៣ឆ្នាំ)
គឺបានផ្តល់សិទ្ធទូលំទូលាយនិងមានអាទិភាពច្រើននៅក្នុងការស្នើសូមដកប្រាក់ធានារ៉ាប់រង

P9

យៈពេលលអាចស្នើរសូម(៣ឆ្នាំ)បានកន្លងផុតទៅ មិនបានដាក់ពាក្យសូមដកប្រាក់ធានារ៉ាប់រងពួកគេអាចស្នើសូមដកប្រាក់នោះ
តាមរយៈនាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សនៃប្រទេសកូរេមជ្ឈមណ្ឌលEPS,ស្ថាប័នដែលបញ្ជូនពលករ។ល។នោះគេនិង
ស្វែងរកប្រាក់ដែលមិនបានដកនោះជូន

*ទោះបីជារយៈពេលដែលដាក់ពាក្យសូមដកប្រាក់ធានារ៉ាប់រងបានកន្លងផុតក៏ដោយប្រសិនបើពួកគេដាក់ពាក្យសូមដកប្រាក់
មជ្ឈមណ្ឌលEPSនិងស្ថាប័នដែលបញ្ជូនពលករនោះគឺអាចត្រូវបានផ្តល់ជូន។
(ជំនួសអោយក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងមជ្ឈមណ្ឌលEPS,ស្ថាប័នដែលបញ្ជូនពលករជាអ្នកជាអ្នកទទួលពាក្យ)

7)ពេលបច្ចុប្បនសេដ្ឋកិច្ចក្រុមហ៊ុនគឺមិនសូវល្អ,ក្រោយពេលត្រលប់ទៅដល់ប្រទេសវិញនោះ ករណីបែបនេះការទទួល
ប្រាក់ធានារ៉ាប់រងវាមិនកាន់តែពិបាកទេរឺ?

ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់គឺមិនមែនទទួលពីនិយោជកទេ, នៅពេលដែលចុះកិច្ចសន្យារវានិយោជកនិង
ពលករបរទេសដើម្បីអោយពលករបានចំនេញក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងជាអ្នកសន្សំទុកអោយ

សរុបមក, មុនពេលត្រលប់ទៅដល់ប្រទេសរបស់ខ្លួនវិញពលករបរទេសត្រូវទៅក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងដើម្បីដាក់ពាក្យសូមដកប្រាក់ធានារ៉ាប់រង, គឺគ្មានជាប់ពាក់ពន្ធ័ជាមួយសេដ្ឋកិច្ចក្រុមហ៊ុនឬក៏បញ្ហាប្រាក់ខែទេអោយតែពលករបរទេសដាក់ពាក្យសូមដកប្រាក់
ទៅក្រុមហ៊ុនសេវាកម្មធានារ៉ាប់រងនោះគឺគេនិងផ្តល់ជូន

8)ក្នុងករណីដែលពលករបរទេសបានផ្លាស់ប្តូរកន្លែងការងារ, តើក្រុមហ៊ុនមុនផ្តល់ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់
អោយដែរឺទេ?

យោងតាមច្បាប់ដែលបានកែសំរួល, បើទោះពលករបរទេសបានផ្លាស់ប្តូរកន្លែងការងារ,ទាំងក្រុមហ៊ុនមុនទាំងក្រុមហ៊ុនដែលបានធ្វើការចុងក្រោយបង្អស់គឺក្រោយការវិលត្រលប់រួចក្នុងអំពេល១៤ថ្ងៃទើបផ្តល់ជូនគឺសរុបទាំងអស់

*ឧទាហរណ៍ )ក្នុងអំឡុងពេលស្នាក់នៅគេបានធ្វើការងារនៅក្រុមហ៊ុន៣គឺA,B,C រួចហើយនៅពេលដែលលារឈប់គឺនៅក្រុមហ៊ុន C ដែលជាក្រុមហ៊ុនចុងក្រោយបង្អស់, ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់នៃក្រុមហ៊ុន A,B,C ត្រូវបានប្រមូលដាក់រួមគ្នា
ហើយនិងផ្តល់ជូននៅពេលដែលធ្វើការវិលត្រលប់រួច។

ក្នុងករណីដលប្រាក់ធានារ៉ាប់រងតិចជាងប្រាក់បំណាច់ឆ្នាំចំពោះប្រាក់ដែលខ្វះគឺមិនជាប់ពាក់ពន្ធ័ទៅនិងការវិលត្រលប់ឬ មិនវិល
ត្រលប់នោះទេ ការវិលត្រលប់ឬក៏ផ្លាស់ប្តូរកន្លែងការងារពេលចប់កិច្ចសន្យាពលករបរទេសធ្វើការស្នើរសូមដកប្រាក់នេះដោយផ្ទាល់
ទៅនិយោជកហើយប្រាក់នេះនិងត្រូវផ្តល់ជូននៅក្នុងប្រទេសតែម្តង។

ក្នុងករណីពលករបរទេសផ្លាស់ប្តូរកន្លែងការងារមុនពេលផ្លាស់ប្តូរបើប្រាក់ធានារ៉ាប់រងតិចជាងប្រាក់បំណាច់ឆ្នាំនោះ
គេស្នើរសូមដកប្រាក់ដែលខ្វះនេះបាន។

P10

9 ) ច្បាប់ដែលបានកែសំរួលចាប់អនុវត្តន៏ពីថ្ងៃទី២៩ខែ៧ឆ្នាំ២០១៤, ក្រោយពីច្បាប់ចូលជាធរមាន ២៩.៧.២០១៤
ធ្វើការវិលត្រលប់ តើប្រាក់ធានារ៉ាប់រងនិងត្រូវបានទទួលនៅក្រោយពេលធ្វើការវិលត្រលប់មែនរឺ?

រយៈពេលនៃការផ្តល់ប្រាក់ធានារ៉ាប់រងការវិលត្រលប់តាមពេលកំនត់(ចាប់ពីពេលដែលបានចាកចេញទៅក្នុងអំឡុងពេល១៤ថ្ងៃ)
បញ្ញត្តិនេះនិងចាប់អនុវត្តន៏ក្រោយថ្ងៃដែលច្បាប់ចូលជាធរ័មាននិងចាប់ផ្តើមអនិវត្តន៏ចំពោះអ្នកដែលបានដាក់ពាក្យស្នើសូមប្រាក់
នេះនៅក្រោយពេលដែលច្បាប់ដំណើរការ(ច្បាប់ពូឈិកមាត្រាទី២)

សរុបមក, លិខិតជូនដំណឹងស្តីអំពីការវិលត្រលប់ ឬក៏លិខិតការផ្លាស់ប្តូរការងារនៃពលករបរទេស '២៩,៧,២០១៤'
ដែលបានដាក់ពាក្យស្នើសូមប្រាក់ធានារាប់រងមុនថ្ងៃនេករណីបែបនេះទោះបីជាច្បាប់បានដំណើរការ(២៩,៧,១៤)
ហើយ ធ្វើការវិលត្រលប់ក៏ដោយការផ្តល់ប្រាក់គឺដូចមុនគឺទទួលនៅក្នុងប្រទេសកូរេ

ឧទាហរណ៍) ① លិខិតជូនដំណឹងាស្តីអំពីការវិលត្រលប់ និងលិខិតការផ្លាស់ប្តូរការងារនៃពលករបរទេស '២៨,៧,២០១៤'
ដាក់ពាក្យស្នើសូមប្រាក់ធានារាប់រងករណីនេះគឺរក្សារដូចមុនទទួលប្រាក់នៅក្នុងស្រុករួចទើបធ្វើការវិលត្រលប់

② លិខិតជូនដំណឹងស្តីអំពីការវិលត្រលប់ និងលិខិតការផ្លាស់ប្តូរការងារនៃពលករបរទេស '២៩,៧,២០១៤'
ដាក់ពាក្យស្នើសូមប្រាក់ធានារាប់រងករណីនេះគឺធ្វើការវិលត្រលប់រួចហើយ ទើបអាចទទួលប្រាក់ធានារាប់រងបាន

10)ករណីដែលប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមកំនត់តិចជាងប្រាក់បំណាច់ឆ្នាំនិយោជកត្រូវតែបន្ថែមប្រាក់ដែលខ្វះនេះអោយមែនដែរឺទេ?

「តាមច្បាប់ស្តីអំពីប្រាក់បំណាច់ឆ្នាំនៃកម្មករ」បានកំនត់ប្រាក់បំណាច់ឆ្នាំអប្បបរមា ករណីដែលប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមកំនត់តិចជាងប្រាក់បំណាច់ឆ្នាំដែលច្បាប់បានកំនត់,នោះនិយោជកត្រូវតែផ្តល់បន្ថែមអោយនូវប្រាក់ដែលខ្វះនេះ

<ចំនួន ប្រាក់បំណាច់ឆ្នាំ —ចំនួន ប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមពេកកំនត់ =ចំនួន ប្រាក់ដែលក្រុមហ៊ុនត្រូវផ្តល់បន្ថែម >

11) ប្រាក់បំណាច់ឆ្នាំដែលច្បាប់បានកំនត់និងសេវាកម្មធានារ៉ាប់រងប្រាក់ការវិលត្រលប់មានចំនួនខុសគ្នាតើប្រាក់ដែលខ្វះ
នោះនិងត្រូវទទួលនៅក្រោយពេលវិលត្រលប់រួចមែនដែរឺទេ?

ប្រាក់បំណាច់ឆ្នាំដែលច្បាប់បានកំនត់និងប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមកំនត់មានចំនួនខុសគ្នាចំពោះប្រាក់ដែលខ្វះ
គឺមគ្មានជាប់ពាក់ពន្ធ័ទៅនិងការវិលលប់ឬក៏ការផ្លាស់ប្តូរការងារនោះទេនៅពេលលាឈប់ពីការងារគឺត្រូវស្នើរសូមដកប្រាក់ទៅ
និយោជកដោយផ្ទាល់ពីព្រោះប្រាក់នេះអាចទទួលនៅក្នុងស្រុកបាន
* ប្រាក់បំណាច់ឆ្នាំដែលច្បាប់បានកំនត់និងប្រាក់ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមកំនត់មានចំនួនខុសគ្នាចំពោះប្រាក់ដែលខ្វះ
សំរាប់ច្បាប់ដែលបានកែសំរួលគឺគ្មានការប្រែប្រួលទេ

## P11

12) នៅមុនពេលធ្វើការវិលត្រលប់ដាច់ខាតត្រូវតែដឹងអោយច្បាស់អំពីចំនួនទឹកប្រាក់ដែលខ្វះបណ្តាលមកពីប្រាក់ធានារ៉ាប់រង
និងប្រាក់បំណាច់ឆ្នាំមានចំនួនខុសគ្នាហើយប្រាក់នេះអាចស្នើសូមដកពីនិយោជកបានតើត្រូវឆែកមើលតាមរបៀបណាដែរ?

បច្ចុប្បន្ននេះដោយផ្អែកលើលក្ខន្តិកៈកិច្ចសន្យា យើងអាចឆែកមើលប្រាក់ធានាររាប់រងមុនពេលដែលត្រូវទទួលបាន,

ហើយដើម្បីអោយកាន់តែច្បាស់លាស់ជាងនេះទៅទៀតនោះ អ្នកប្រើប្រាស់ឬក៏ពលករបរទេសអាចស្នើរទៅអ្នកទទួលបន្ទុកសេវាកម្មធានារាប់រងសូមពិនិត្យមើលតារាងបញ្ជីទឹកប្រាក់,ក្នុងករណីនេះអ្នកទទួលបន្ទុកប្រាក់ធានារាប់រងនិងប្រគល់បញ្ជីទឹកប្រាក់បណ្តោះ
អាសន្នអោយទៅអ្នកស្នើសូមភ្លាមៗ។

តាមរយៈសកម្មភាពខាងលើនេះនៅពេលដែលពលករបរទេសដាក់ពាក្យសូមដកប្រាក់ធានារាប់រងមុនពេលធ្វើមាតុភូមិនិវត្តន៏
ដោយសារបញ្ជីនេះគេអាចដឹងជាមុននូវចំនួនទឹកប្រាក់ដែលនិងទទួលបាន,វាគឺជាភស្តុតាងដែលអាចសូមដកប្រាក់ដែលខ្វះ
ពីនិយោជកបាន

## P12

មន្ទីការងារ លេខទូរសព្ទ័

※ មន្ទីការងារ មជ្ឈមណ្ឌលពិគ្រោះពត៏ទូទៅ

- 1544 - 1350 (ជនជាតិកូរេ) / លេខទូរសព្ទ័ 1350 (ជនបរទេស/ភាសារអង់គ្លេស, ភាសារចិន)

| លេខរាង | ឈ្មោះមន្ទី | អាសយ័ដ្ឋាន | លេខទូរសព្ទ័ |
|---|---|---|---|
| 1 | មន្ទីការងារសេអ៊ូល | ទីក្រុងសេអ៊ូល ជុងគូ ចាងក្យូដុងទី១ អាគារចាងក្យូប៊ីលឌីងជាន់ទី៤ | 02-2004-7397 |
| 2 | មន្ទីការងារសេឆ្វ | ទីក្រុងសេអ៊ូល សឆូរគូ បាងប៉ែ ៣ ដុង ១០២២—១០ | 02-580-4983 |

| | | | |
|---|---|---|---|
| 3 | មន្ទីការងារសេអ៊ូលកាង<br>ណាម | ទីក្រុងសេអ៊ូល ខាងណាមគូ ដេឈីដុង ៨៨៩– យើមខាងថាវ័រជាន់ទី ៧〜១០ | 02-3468-4794 |
| 4 | មន្ទីការងារសេអ៊ូលដុងប៊ូ | ទីក្រុងសេអ៊ូល សូងផាគូ ការាក់ដុង ៧៨ សូងផាIT ប៉ែនឆរថាវ័រ ដុងក្ខាន់ជាន់ទី ៣〜៥ | 02-2142-8924 |
| 5 | មន្ទីការងារសេអ៊ូលសប៊ូ | ទីក្រុងសេអ៊ូល ម៉ារផូគូ ដូហ្វាដុង ១៧៣ សាមឆាំងផ្លាហ្សាប៊ីលឌីងជាន់ទី ៣〜៥ | 02-2077-6000 |
| 6 | មន្ទីការងារសេអ៊ូលណាមប៊ូ | ទីក្រុងសេអ៊ូល យ៉ុងទើងផូរគូ យ៉ាងផ្យង់ដុង ១ ខា ១១៥ បុនជី | 02-2639-2300 |
| 7 | មន្ទីការងារសេអ៊ូលបុកប៊ូ | ទីក្រុងសេអ៊ូល ណូវ៉ុនគូ សាងគែ ៦ ដុង ៧៣៤–២ | 02-2171-1816 |
| 8 | មន្ទីការងារសេអ៊ូលក្វាន់អាក់ | ទីក្រុងសេអ៊ូល គួរ៉ូគូ គួរ៉ូ ៣ ដុង ១៨២-4 ដេរ៉ូងប៉ុស្តិ៍ថាវ័រ ៣ ឆា ជាន់ទី ២〜៣ | 043-845-7114 |
| 9 | មន្ទីការងារអ៊ីនឆុន | ទីក្រុងអ៊ីនឆុន ណាមដុងគូ គូវ៉ល ៣ ដុង ១១១២ បុនជី( ផ្លូវមូនហ្វាហ្វេក្វាន់ ១២៥) | 032-460-4701 |
| 10 | មន្ទីការងារអ៊ីនឆុនបុកប៊ូ | ទីក្រុងអ៊ីនឆុន ខេយ៉ាងគូ ខេសាន់ដុង ១០៦៣–១២ អាគារយ៉ុងសាន់ជាន់ទី២–៥ (ចាងថ៌ែរ៉ូ ១០៣២) | 032-540-5718 |
| 11 | មន្ទីការងារប៊ូឆុន | ក្យុងគីដូ ប៊ូឆន់ស៊ី វ៉ុនមីគូ ជូង ៣ ដុង ១០៨៦–៣( ខេណាមយើនឃើល២៣៥) | 032-320-8900 |
| 12 | មន្ទីការងារគីមផូ | ក្យុងគីដូ គីមផូរស៊ី ចាងគីដុង ១៦០៤ អាគារជើលថាវ័រជាន់ទី ៣〜៥ | 031-999-0912 |
| 13 | មន្ទីការងារអ៊ីយចុងប៊ូ | ក្យុងគីដូ អ៊ីយចុងប៊ូស៊ី ខានើងដុង ៧៥៤ ស៊ីនដុងអាផាភាឌីអ៊ុមប៊ីលឌីងជាន់១-២ | 031-828-0812 |
| 14 | មន្ទីការងារគូរី | ក្យុងគីដូ គូរីស៊ី អ៊ីនឆាងដុង ៦៧០–១ផៃយ៉ុងប៊ីលឌីងជាន់ទី២ | 031-560-5840 |
| 15 | មន្ទីការងារណាមយ៉ាងជូ | ក្យុងគីដូ ណាមយ៉ាងជូស៊ី ក្យុងឈូនរ៉ូ ៩៥៣ គើមម៉ារូផ្លាហ្សាជាន់ទី៣ | 031-560-1991 |
| 16 | មន្ទីការងារកូយ៉ាង | ក្យុងគីដូ កូយ៉ាងស៊ី អ៊ីលសានដុងគូ ចាងហាងដុង ៧៣៦–២, រ៉ូដេអូថាវ័រប៊ីលឌីង | 031-920-3951 |
| 17 | មន្ទីការងារស៊ូវ៉ុន | ក្យុងគីដូ ស៊ូវ៉ុនស៊ី ផាល់តាល់គូ អ៊ីកែដុង ៩៣៩ស៊ីនដុងអាផាសីថេលជាន់ទី២-៤ | 031-231-7864 |
| 18 | មន្ទីការងារយ៉ូងអ៊ីន | ក្យុងគីដូ យ៉ុងអ៊ីនស៊ី គីហ៊ឹងគូ គូកាល់ដុង ៥៨១–១ ខាងណាមអ៊ែនអើលរុសីប៊ីលឌីងជាន់ទី៣〜៤ | 031-289-2210 |
| 19 | មន្ទីការងារហ្វាសុង | ក្យុងគីដូ ហ្វាសុងស៊ី ប៉ុងតាមអ៊ឹប ដុងហ្វារី ៥៥៩–២ អ៊ីវ៉ុនថាវ័រជាន់ទី៧ | 031-290-0870 |
| 20 | មន្ទីការងារសុងណាម | ក្យុងគីដូ សុងណាមស៊ី ជូងវ៉ុនគូ ដូឆូនដុង ៥៦៩ដូឆូនទេដុកភើរាសា២ឆាជាន់ទី៤〜៦ | 031-739-3161 |
| 21 | មន្ទីការងារក្យុងគីដូក្វាងជូ | ក្យុងគីដូ ក្វាងជូស៊ី យ៉ក់ដុង ២៧–៨៦ (ផ្លូវក្វាងជូ ២១៦) សុនហ្វាប៊ីលឌីងជាន់ទី៣.៤ | 031-799-2740 |
| 22 | មន្ទីការងារអ៊ីឆុន | ក្យុងគីដូ អ៊ីឆុនស៊ី ឆាងចុនដុង ៤៤៣–៣៧ វ៉ុនប៊ីលឌីងជាន់ទី១–៣ | 031-644-3811 |
| 23 | មន្ទីការងារអាន់យ៉ាង | ក្យុងគីដូ អាន់យ៉ាងស៊ី ម៉ាន់អាន់គូ អាន់យ៉ាង៤ ដុង ៦៧៦–៩១បុនជីអាន់យ៉ាងមេសេថាវ័រជានទី៤ | 031-463-0771 |
| 24 | មន្ទីការងារក្វាងម្យូង់ | ក្យុងគីដូ ក្វាងម្យូង់ស៊ី ឆុលសានដុង ៤៦៣–៣៨ហ៊ីលអែលរីសីជានទី១-២ | 02-2680-1500 |
| 25 | មន្ទីការងារអាន់សាន | ក្យុងគីដូ អាន់សានស៊ី ដាន់វ៉ុនគូ កូចាន់ដុង ៥២០–១(ផ្លូវវ៉ុនកូចាន់១១) | 031-412-6954 |
| 26 | មន្ទីការងារស៊ីហ៊ឹង | ក្យុងគីដូ ស៊ីហ៊ឹងស៊ី ចុងវ៉ាំងដុង ៣៣–១ ចុងវ៉ាំងផ្លាហ្សាជាន់ទី៣ | 031-496-1909 |
| 27 | មន្ទីការងារផ្យ៉ង់ថែក | ក្យុងគីដូ ផ្យ៉ង់ថែកស៊ី អ៊ីឈូងដុង ៦០៦ ចាងដាងផ្លាហ្សាជាន់ទី២( ជូងអាងរូ ៤ កា ៦០ បុនជី) | 031-646-1258 |
| 28 | មន្ទីការងារឈូនឆុន | កាងវ៉ុនដូ ឈូនឆុនស៊ី សុកសាដុង ៨៨៥– ៣ ណោកសសឹផ្លាហ្សាជាន់ទី ២–៥ | 033-250-1900 |

| | | | |
|---|---|---|---|
| 29 | មន្ទីការងារកាងនើង | កាងវ៉ុនដូ កាងនើងស៊ី ក្យ៉ូដុង ១០០៣−១៨ ស៊ីនហ្យ៉ប់ប៊ីលឌីង | 033-610-1919 |
| 30 | មន្ទីការងារវ៉ុនជូ | កាងវ៉ុនដូ វ៉ុនជូស៊ី គែអ៊ូនដុង ៤៥១−៤ ហាន់ស៊ីនផ្លាហ្សាជាន់ទី៣ | 033-769-0900 |
| 31 | មន្ទីការងារផែពែក | កាងវ៉ុនដូ ផែពែកស៊ី ផ្លូវបុនយ៉ុង ៣៤១ | 033-552-8605 |
| 32 | មន្ទីការងារសាមឆុក | កាងវ៉ុនដូ សាមឆកស៊ី ណាមយ៉ាងដុង ៣៣២ អាគារហ្យ៉ុនជីនជាន់ទី៤ | 033-573-9914 |
| 33 | មន្ទីការងារយ៉ុងវ៉ល | កាងវ៉ុនដូ យ៉ុងវ៉លគូន យ៉ងវ៉លអ៊ឹប យ៉ងហ៊ឹង៥ រី ៩៧៦-១( បូនសូ សូថៃ) | 033-371-6260 |
| 34 | មន្ទីការងារប៊ូសាន | ប៊ូសានស៊ី ជីនគូ យ៉ាងចុងដុង ១៥០−៣ (មន្ទីការងារប៊ូសាន) | 051-860-1919 |
| 35 | មន្ទីការងារប៊ូសានដុងប៊ូ | ប៊ូសានស៊ី ស៊ូយ៉ុងគូ ក្វាងអាន់ដុង ៨៩−១៨ (អាគារមន្ទីការងារ) | 051-760-7103 |
| 36 | មន្ទីការងារប៊ូសានបុកប៊ូ | ប៊ូសានស៊ី បុកគូ ហ្វាម៉ូង ៣ដុង ២២៧០−៣ អាគារមជ្ឈមណ្ឌលជាន់ទី១−៥ | 051-330-9900 |
| 37 | មន្ទីការងារឆាងវ៉ុន | ក្យុងសាងណាមដូ ឆាងវ៉ុន់ស៊ី សាងណាមដុង ២៧−៣(អាគារន្ទីការងារ ជាន់ទី៦) | 055-239-0900 |
| 38 | មន្ទីការងារអ៊ូលសាន | អ៊ូលសានស៊ី ណាមគូ សាមសានដុង១៦០៤−២ | 052-228-1919 |
| 39 | មន្ទីការងារគីមហ៊ែ | ក្យុងសាងណាមដូ គីមហ៊ែស៊ី ប៊ូវ៉ុនដុង ៦១១−៥ | 055-330-6421 |
| 40 | មន្ទីការងារយ៉ាងសាន | ក្យុងសាងណាមដូ យ៉ាងសានស៊ី ជូងប៊ូដុង ៦៨៥−១ | 055-379-2400 |
| 41 | មន្ទីការងារជីនជូ | ក្យុងសាងណាមដូ ជីនជូស៊ី ចាងឌែដុង ១២៧−១២ អាគារអាន់សង់ជាន់ទី២~៥ | 055-760-6743 |
| 42 | មន្ទីការងារថុងយ៉ុង | ក្យុងសាងណាមដូ ថុងយ៉ុងស៊ី ក្វាងដូមូន់ ជូកលីមលី ១៥៨០−១៨ | 055-650-1800 |
| 43 | មន្ទីការងារឌែគូ | ឌែគូស៊ី ស៊ូសុងគូ ប៉ម៉ដុង ៤៥−៣១ | 053-667-6000 |
| 44 | មន្ទីការងារដេគូសរប៊ូ | ឌែគូស៊ី សរគូ នែដាងដុង ៤៦៩−៣ | 053-605-6500 |
| 45 | មន្ទីការងារផូហាង | ក្យុងសាងប៉ុកដូ ផូហាងស៊ី ប៉ុកគូ ជូកដូដុង ៦១៨−៣ | 054-280-3000 |
| 46 | មន្ទីការងារក្យ៉ង់ជូ | ក្យុងសាងប៉ុកដូ ក្យុងងជូស៊ី សុងដុងដុង៥៩−៥ សង់ដុងសែ៊ម៉ាអ៊ឹលគើមកូជាន់ទី ៣,៤ | 054-778-2500 |
| 47 | មន្ទីការងារគូមី | ក្យុងសាងប៉ុកដូ គូមីស៊ី សុងចុងដុង ៥២, លេខ៥២−៤(ផ្លូវ ប៉ែកសាន១០៨) | 054-440-3300 |
| 48 | មន្ទីការងារយ៉ុងជូ | ក្យុងសាងប៉ុកដូ យ៉ុងជូស៊ី វ៉ុនដាងរ៉ូ ៦៨(ហ្យ៊ូនុន ៣ ដុង លេខ៣៦) | 054-639-1136 |
| 49 | មន្ទីការងារមូនក្យ៉ង់ | ក្យុងសាងប៉ុកដូ មូនក្យុងស៊ី ម៉ូចុនរ៉ូ ៨៥−៣ | 054-559-8232 |
| 50 | មន្ទីការងារអាន់ដុង | ក្យុងសាងប៉ុកដូ អាន់ដុងស៊ី ក្យុងងដុងរ៉ូ ៤០០ | 054-851-8041 |
| 51 | មន្ទីការងារក្វាងជូ | ក្វាងជូ ប៊ូកគូ ប៊ូកដុង ១៩០−១ | 062-609-8500 |
| 52 | មន្ទីការងារចុនជូ | ចុលាបុកដូ ចុនជូស៊ី តុកជីនគូ ផែផ្យង់រ៉ូ ៧៩ (ជីនបុកដុង ៤១០−១) | 063-270-9100 |
| 53 | មន្ទីការងារអ៊ីកសាន | ចុលាបុកដូ អ៊ីកសានស៊ី អ៊ីកសានឌែរ៉ូ ៥២ ផ្លូវលេខ១១ | 063-840-6526 |
| 54 | មន្ទីការងារគូនសាន | ចុលាបុកដូ គូនសានស៊ី ចូងូនរ៉ូ ៦២ | 063-450-0600 |
| 55 | មន្ទីការងាម៉ុកផូរ | ចុលាណាមដូ ម៉ុកផូស៊ី សាងដុង ១១២១−៤ | 061-280-0500 |

| | | | |
|---|---|---|---|
| 56 | មន្ទីការងារស៊ុនឆុន | ចុលាណាមដូ ស៊ុនឆុនស៊ី ចូញ្ញៀដុង ឈរខ ១២៤៥ | 061-720-9114 |
| 57 | មន្ទីការងារយ៉ស៊ូ | ចុលាណាមដូ យ៉រស៊ូស៊ី មូនស៊ូដុង ១១១−១( បូនស្វរ ស្វចៃ) | 061-6500-155 |
| 58 | មន្ទីការងារខែចុន | ខែចុន សរគូ ថាន់ប៉ាង់ដុង ៦៥៩ | 042-480-6000 |
| 59 | មន្ទីការងារឆុងជូ | ឈូងឆុងបុកដូ ឆុងជូស៊ី ហ៊ឹងងតុកគូ សាឆាងដុង ១៧១−៥វ៉លឌើភីអាអូស ភីសឹថេលជាន់ទី ២-៤ | 043-230-6700 |
| 60 | មន្ទីការងារឆុនអាន់ | ឈូងឆុងណាមដូ ឆុនអាន់ស៊ី សរបុកគូសង់ចង់ដុង ១៤៣៧ ឈូងណាមថាវ័រជាន់ ទី ២−៥ | 041-620-7400 |
| 61 | មន្ទីការងារឈូងជូ | ឈូងឆុងប៉ុកដូ ឈូងជូស៊ី មូនហ្វាដុង ៥០៧ | 043-850-4000 |
| 62 | មន្ទីការងារបូរ៉ាង់ | ឈូងឆុងណាមដូ បូរ៉ាង់ស៊ី មូង់ឆុនដុង ៤៩៨−៦ | 041-930-6200 |



P14

អ្នកទទួលបន្ទុកសេវាកម្មធានារ៉ាប់រង(សាមសុងហ្វាជៃ ខុនស្វស៊ីអុំ) លេខទូរសព្ទ័

ក្រុមហ៊ុនធានារ៉ាប់រងសាមសុងហ្វាជៃ(ខូ.,អិលធីឌី.) ក្រុមហ៊ុនធានារ៉ាប់រងហ្យ៊ូន់ខៃហ៊ៃសាងហ្វាជៃ(ខូ.,អិលធីឌី.) ក្រុមហ៊ុនធានារ៉ាប់រង

អិលអាយជីស៊ុនហ៊ៃ(ខូ.,អិលធីឌី.) ក្រុមហ៊ុនដុងប៊ូហ្វាជៃហ៊ៃសាង(ខូ.,អិលធីឌី.) ក្រុមហ៊ុនធានារ៉ាប់រងហាន់ហ្វាស៊ុនហ៊ៃ(ខូ.,អិលធីឌី.)

ប្រភេទសេវាកម្ម : ទិញសេវាកម្មធានារ៉ាប់រង, ស្នើសូមដកប្រាក់ធានារ៉ាប់រងនិងផ្តល់ប្រាក់ធានារ៉ាប់រង

ធានារ៉ាប់រងប្រាក់ការវិលត្រលប់តាមពេលកំនត់ ធានារ៉ាប់រងលើសោហ៊ុយធ្វើមាតុភូមិនិវត្តន៍ ធានារ៉ាប់រងចំពោះឧប្បត្តិហេតុផ្សេងៗ

: មជ្ឈមណ្ឌលទំនាក់ទំនងសាមសុងហ្វាជៃ និងមជ្ឈមណ្ឌលផ្តល់ពត៏១៦កន្លែង

— មជ្ឈមណ្ឌលទំនាក់ទំនងសំរាប់តែផ្នែកធានារ៉ាប់រង : សេអ៊ូល យ៉ុងសាន ហាន់កាងខ្សែរ៣៨យីល ៣៧(យ៉ុងសានដុង៥កា)

ទូរសព្ទ័លេខ : 02-2119-2400 (www.samsungfire.com)

— ទីតាំងមជ្ឈមណ្ឌលផ្តល់ពត៏ទាំង១៦កន្លែង

| លេខរាង | ឈ្មោះក្រុមហ៊ុន | អាសយ័ដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|
| 1 | សាមសុងហ្វាជៃ | ក្បុងគីដូ ស៊ូវ៉ុនស៊ី ផាល់តាល់គូ ក្វន់ក្វាងរ៉ូ ២០៥, អាគារសាមសុងហ្វាជៃជាន់ទី ៣(អ៊ីនកែដុង) | 031-230-1042 |
| 2 | | ក្បុងគីដូ អាន់សានស៊ី ដាន់វ៉ុនគូ ក្វាងដក់ខ្សែរ៉ូ ២៥៩ អាគារសាមសុងហ្វាជៃជាន់ទី១(កូចាន់ដុង) | 031-413-7144 |

| | | | |
|---|---|---|---|
| 3 | | ក្សុងគីដូ អ៊ីយចុងប៊ូស៊ី ស៊ីមីនរ៉ូ ៦២ សាមសុងស៊ាំងម្ងង់អ៊ីយចុងប៊ូសាអូក ជាន់ទី៣ (អ៊ីយចុងប៊ូដុង) | 031-876-8115 |
| 4 | | ឈ្យូងណាម ឆុនអាន់ស៊ី ដុងណាមគូ ឆុងស៊ូ ១៤ រ៉ូ ពែកសកម្ងូនហ្វាសេនធើ ជាន់ទី៩ (ឆុងដាងដុង) | 041-559-3714 |
| 5 | | ក្សុងណាម ឆាងវ៉ុនស៊ី ម៉ាសានហ្វេវ៉ុនគូ ៣.១៥ ឌែរ៉ូ ៦៧៤ អាគារសាមសុងហ្វាដែជាន់ទី២ (សកចុនដុង) | 055-250-2518 |
| 6 | | ក្សុងគីដូ សុងណាមស៊ី ស៊ូចុងគូ ១សុងណាមឌែរ៉ូ ១១៧១អាគារសាមសុងហ្វាដែជាន់ទី(ស៊ូជីនដុង) | 031-758-8114 |
| 7 | | ក្សុងគីដូ ផ្យ៉ង់ធែកស៊ី ក្សុងគីឌែរ៉ូ ២៦១ អាគារ BYC ជាន់ទី៥( ប៊ីចុនដុង) | 031-657-6094 |
| 8 | | ឈ្យូងបុក ឈ្យូងជូស៊ី គុកវ៉ុនថឌែរ៉ូ ១១៣ អាគារ BYC ជាន់ទី៣( ក្សូហ្យ៉ន់ដុង) | 043-845-7114 |
| 9 | ហ្យ៉ន់ខែហ៊ែសាង | ក្សុងគីដូ ស៊ូវ៉ុនស៊ី ក្វន់សុនគូ ហ្យ៉ូវ៉ុនរ៉ូ ២៦៨ហ្យ៉ន់ខែហ៊ែសាង អាគារជាន់ទី១ (ក្វន់សុនដុង) | 031-230-0543 |
| 10 | | ទីក្រុងអ៊ីនឆុន ណាមដុងគូ មីឆ៊ូរ៉ូ ៧ ហ្យ៉ន់ខែហ៊ែសាងអាគារជាន់ទី១ (គូវ៉លដុង) | 032-222-1206 |
| 11 | | ប៊ូសាន ដុងគូ ជូងអាងឌែរ៉ូ ២៤០ ហ្យ៉ន់ខែហ៊ែសាងប៊ូសានសាអូកជាន់ទី២ (ឆូញាងដុង) | 051-960-1025 |
| 12 | | ក្វាងជូស៊ី សរគូ ស៊ីឆុងរ៉ូ ៧២ ហ្យ៉ន់ខែហ៊ែសាងអាគារជាន់ទី២ (ឈីផ្យង់ដុង) | 062-350-1424 |
| 13 | | អ៊ូលសានស៊ី ណាមគូ បន់យ៉ុងរ៉ូ ១៣១ហ្យ៉ន់ខែហ៊ែសាងអាគារជាន់ទី២ (ដាលដុង) | 052-229-1211 |
| 14 | អិលអាយជីសូនបូ | ចុលបុក អ៊ីកសានស៊ី ហាណារ៉ូ ៤៦៤ ខែសុងប៊ីលឌីង ជាន់ទី៤ (អរយ៉ាងដុង) | 063-839-3983 |
| 15 | ដុងប៊ូហ្វាដែ | ខែគូ ជូងគូ ដាល់គូបុលឌែរ៉ូ ២០៥៨ អាល់លីអាន់ឈើ ថាវ័ជាន់ទី១២ (ណាមសានដុង) | 053-251-4137 |
| 16 | ហាន់ហ្វាសូនបូ | អ៊ីឆុនស៊ី ប៊ូផ្យ៉ង់គូ ប៊ូផ្យ៉ង់ឌែរ៉ូ ៧៥ ខែហាន់ស៊ាំងម្ងង់អាគារជាន់ទី៩ (ប៊ូផ្យ៉ង់ដុង) | 032-501-2181 |

P15

នាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សនៃប្រទេសកូរ៉េ លេខទូរសព្ទ

| លេខរាង | ឈ្មោះក្រុមហ៊ុន | អាសយដ្ឋាន | លេខទូរសព្ទ |
|---|---|---|---|
| | ទីស្នាក់ការកណ្តាលនាយកដ្ឋាន | អ៊ូលសានស៊ី ជូងគូ ចូងការ៉ូ ៣៤៥ | 052-714-8572 |
| 1 | ទីស្នាក់ការកណ្តាលក្រុងសេអ៊ូល | សេអ៊ូលស៊ី ម៉ាផូគូ ពែកប៉មរ៉ូ ៣១ឃីល ២១ | 02-3274-9621 |
| 2 | ទីស្នាក់ការសេអ៊ូលដុងប៊ូ | សេអ៊ូល ក្វាងជីនគូ តុកសុមរ៉ូ ៣២ឃីល ៣៨ | 02-2024-1755 |
| 3 | ទីស្នាក់ការសេអ៊ូលណាមប៊ូ | សេអ៊ូល យ៉ុងទើងផូគ ប៉ខើណារ៉ូ ១១០ | 02-6907-7120 |
| 4 | ទីស្នាក់ការកាងវ៉ុន | កាងវ៉ុនដូ ឈ្យូនឆុនស៊ី ដុងនែម្ងន់ វ៉ុនឆាងកូគែឃីល ១៣៥ | 033-248-8506 |
| 5 | ទីស្នាក់ការកាងនើង | កាងវ៉ុនដូ កាងងនើងស៊ី សាឆុនម៉ូន ប៉ាងដុងឃីល ៦០ | 033-650-5722 |

| | | | |
|---|---|---|---|
| 6 | ទីស្នាក់ការកណ្តាលតំបន់ជូងប៊ូ | អ៊ីនឆុនស៊ី ណាមដុងគូ ណាមដុងសរ៉ូ ២០៩ | 032-820-8652 |
| 7 | ទីស្នាក់ការក្យុងគីដូ | ក្យុងគីដូ ស៊ូវ៉ុន់ស៊ី ក្វន់សុនគូ ហ្វមែស៊ីលរ៉ូ ៤៦-៦៨ | 031-249-1247 |
| 8 | ទីស្នាក់ការក្យុងគីដូបុកប៊ូ | ក្យុងគីដូ អ៊ីយចុងប៊ូស៊ី ឈ្យូដុងរ៉ូ ១៤០ | 031-850-9132 |
| 9 | ទីស្នាក់ការសុងណាម | ក្យុងគីដូ សុងណាមស៊ី ស៊ូចុងគូ សុងណាមឌែរ៉ូ ១២១៧ | 031-750-6234 |
| 10 | ទីស្នាក់ការកណ្តាលប៊ូសាន | ប៊ូសានស៊ី បុកគូ ឃើមក្វុកឌែរ៉ូ ៤៤១បុនឃីល ២៦ | 051-330-1835 |
| 11 | ទីស្នាក់ការប៊ូសានណាមប៊ូ | ប៊ូសានស៊ី ណាមគូ ស៊ីនសុនរ៉ូ ៤៥៤-១៨ | 051-620-1935 |
| 12 | ទីស្នាក់ការក្យុងណាម | ក្យុងណាម ឆាងវ៉ុន់ស៊ី ឌូឌែរ៉ូ ២៣៩ | 055-212-7225 |
| 13 | ទីស្នាក់ការអ៊ូលសាន | អ៊ូលសានក្វាងយ៉កស៊ី ណាមគូ បុនយ៉ុងរ៉ូ ១៧៣ | 052-220-3262 |
| 14 | ទីស្នាក់ការកណ្តាលឌែគូ | ឌែគូ ដាលសរគូ សុងសរក្វុងងដាន់រ៉ូ ២១៣ | 053-580-2362 |
| 15 | ទីស្នាក់ការក្យុងបុក | ក្យុងបុក អាន់ដុងស៊ី សរហ៊ូមូន់ ហាក់ការសានអូនឆុនឃីល ៤២ | 054-840-3021 |
| 16 | ទីស្នាក់ការផូហាង | ក្យុងបុក ផូហាងស៊ី បុកគូ បុបវ៉ុន់រ៉ូ ១៤០បុនឃីល ៩ | 054-251-8517 |
| 17 | ទីស្នាក់ការកណ្តាលក្វាងជូ | ក្វាងជូស៊ី ពូកគូ ឆំដាន់បេនឆររ៉ូ ៨២ | 062-970-1751 |
| 18 | ទីស្នាក់ការចុលបុក | ចុលបុក ចុនជូស៊ី ដុកជីនគូយូសាងរ៉ូ ៦៩ | 063-210-9202 |
| 19 | ទីស្នាក់ការចុលណាម | ចុលណាម ស៊ូនឆុនស៊ី ស៊ូនក្វាងរ៉ូ ៣៥-២ | 061-720-8522 |
| 20 | ទីស្នាក់ការម៉ូកផូ | ចុលណាម ម៉ុកផូស៊ី យ៉ុងសានរ៉ូ ៨២០ | 061-288-3333 |
| 21 | ទីស្នាក់ការចេជូ | ចេជូ ចេជូស៊ី បុកជីរ៉ូ ១៩ | 064-729-0725 |
| 22 | ទីស្នាក់ការកណ្តាលឌែចុន | ឌែចុនស៊ី ជូងគូ សរមូនរ៉ូ ២៥បុនឃីល ១ | 042-580-9162 |
| 23 | ទីស្នាក់ការឈ្យូងបុក | ឈ្យូងបុក ឆុងជូស៊ី ហ៊ឹងដុកគូ ១ស៊ូនហ្វាន់រ៉ូ៣៩៤ឃីល ៨១ | 043-279-9016 |
| 24 | ទីស្នាក់ការឈ្យូងណាម | ឈ្យូងណាម ឆុនអាន សរគូ ឆុនអ៊ីលក្វ១ឃីល ២៧ | 041-620-7625 |

នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃប្រទេសកូរ៉េ លេខទូរសព្ទ័ : 1644-8000 មជ្ឈមណ្ឌលគាំពារជនបរទេស : 1577-0071



www.hrdkorea.or.kr

សេវាកម្មធានារ៉ាប់រងទាំង៤ប្រភេទសំរាប់ពលករបរទេសគឺមានដូចខាងក្រោម

•សេវាកម្មធានារ៉ាប់រងប្រាក់ការវិលត្រលប់(បន្ធូបន្ថយការលំបាកក្នុងការផ្តល់ប្រាក់បំណាច់ឆ្នាំ)

•សេវាកម្មធានារ៉ាប់រងលើប្រាក់សោហ៊ុយធ្វើមាតុភូមិនិវត្តន៏(សំរាប់ទិញសំបុត្រយន្តហោះ)

• សេវាកម្មធានារ៉ាប់រលើការបើកប្រាក់ឈ្នួល(ប្រាក់បំរុងសំរាប់ផ្តល់ជូនដល់កម្មករដែលមិនបានទទួលប្រាក់ស្នួល)

•សេវាកម្មធានារ៉ាប់រងចំពោះឧប្បត្តិហេតុ (ប្រាក់បំរុងសំរាប់ករណីទទួលមរណភាព,មានជំងឺផ្សេងៗ)

លេខប្រៃណីយ៍) 681-240 អ៊ូលសានក្វាងយ៉ ជុងគូ ចួងការូ៣៤៥

ទីស្នាក់ការកណ្តាលកំលាំងពលកម្មអន្តរជាតិ ប្រទេសកំលាំងពលកម្ម សេវាកម្មធានារ៉ាប់រងជនបរទេសក្រុមTF—